**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

លេខ : ០៩៨/០៤/២០១៤ កបធ

**សូមក្រាបបង្គំទូលថ្វាយ**
**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

**បពិត្រព្រះករុណា ជាអម្ចាស់ជីវិតតម្កល់លើត្បូង ជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត**

**កម្មវត្ថុ** : សេចក្តីទូលថ្វាយមតិរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ស្តីពីការផ្តើមគំនិតធ្វើសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៧៦ និង មាត្រាទាំងឡាយពីជំពូកទី១៥ ថ្មី ដល់ជំពូកទី១៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

**យោង** : ព្រះរាជសារចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០១៤

ទូលព្រះបង្គំយើងខ្ញុំជាប្រធាននិងសមាជិកសមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានទទួលព្រះរាជសារដូចមានយោងខាងលើ បានរួមប្រជុំក្រុមប្រឹក្សាធម្មនុញ្ញ នៅថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៤ ហើយបានអនុម័តដោយ ៨ សំឡេងលើសមាជិកក្រុមប្រឹក្សាធម្មនុញ្ញទាំងមូល ។ ទូលព្រះបង្គំយើងខ្ញុំសូមព្រះបរមរាជានុញ្ញាតក្រាបបង្គំទូលថ្វាយ**ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត សូមទ្រង់ព្រះមេត្តាជ្រាប ដូចតទៅ :**

**១**-សេចក្តីផ្តើមគំនិតធ្វើវិសោធនកម្មមាត្រា ៧៦ និង មាត្រាទាំងឡាយពីជំពូកទី១៥ ថ្មី ដល់ជំពូកទី ១៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គឺស្របតាមបរិបទនៃការវិវត្តរីកចំរើនរបស់សង្គម ស្របតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យនិងនីតិរដ្ឋ បង្កឱ្យអង្គការរៀបចំការបោះឆ្នោតអនុវត្តសមត្ថកិច្ចរបស់ខ្លួនប្រកបដោយឯករាជ្យនិងអព្យាក្រឹត ធានាឱ្យការបោះឆ្នោតប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវនិងយុត្តិធម៌ ដែលចាំបាច់ត្រូវបញ្ចូលអង្គការរៀបចំការបោះឆ្នោតទៅជាជំពូកថ្មីមួយក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ១៥១ ថ្មី ( មាត្រា ១៣២ ចាស់ ) នៃរដ្ឋធម្មនុញ្ញ ចែងថា “ *ការផ្តើមគំនិតសេរីវី ឬការផ្តើមគំនិតធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញជាសិទ្ធិរបស់ព្រះមហាក្សត្រ របស់នាយករដ្ឋមន្ត្រី និង របស់ប្រធានរដ្ឋសភាតាមសេចក្តីស្នើរបស់តំណាងរាស្ត្រមួយភាគបួននៃចំនួនសមាជិករដ្ឋសភាទាំងមូល ។*

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ / ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh

*ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវធ្វើឡើងដោយច្បាប់ធម្មនុញ្ញមួយដែលអនុម័តដោយរដ្ឋសភា តាមមតិភាគច្រើនពីរភាគបីនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។* »

មាត្រា ១៥២ ថ្មី ( មាត្រា ១៣៣ ចាស់ ) នៃរដ្ឋធម្មនុញ្ញ ចែងថា « *ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញ ត្រូវហាមឃាត់មិនឱ្យធ្វើ នៅពេលប្រទេសជាតិឋិតក្នុងភាពអាសន្ន ដូចមានចែងក្នុងមាត្រា ៨៦ ។* »

មាត្រា ១៥៣ ថ្មី ( មាត្រា ១៣៤ ចាស់ ) នៃរដ្ឋធម្មនុញ្ញ ចែងថា « *ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និង របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ។* »

តាមការពិនិត្យ និង ពិចារណា ដោយផ្អែកតាមបទប្បញ្ញត្តិនៃមាត្រាដូចបានក្រាបបង្គំទូលថ្វាយខាងលើនេះ ខ្លឹមសារនៃសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៧៦ និង មាត្រាទាំងឡាយពីជំពូកទី១៥ ថ្មី ដល់ជំពូកទី១៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ពុំមានអ្វីប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និង របបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញឡើយ ព្រមទាំងធ្វើឡើងនៅក្នុងកាលៈទេសៈធម្មតារបស់ប្រទេសជាតិ ថែមទៀតផង ។

**២**-ក្រុមប្រឹក្សាធម្មនុញ្ញ កត់សម្គាល់លើទម្រង់នៃសេចក្តីព្រាងសេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៧៦ និង មាត្រាទាំងឡាយពីជំពូកទី១៥ ថ្មី ដល់ជំពូកទី១៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឃើញមានខុសអក្ខរាវិរុទ្ធច្រើន ដែលទាមទារឱ្យរដ្ឋសភាកែឱ្យបានត្រឹមត្រូវ ។

**៣**-ក្រុមប្រឹក្សាធម្មនុញ្ញ យល់ឃើញថា សេចក្តីស្នើច្បាប់ធម្មនុញ្ញស្តីពីវិសោធនកម្មមាត្រា ៧៦ និង មាត្រាទាំងឡាយពីជំពូកទី១៥ ថ្មី ដល់ជំពូកទី១៦ ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាខាងលើនេះ អាចធ្វើបាន ។

**សូមព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ទ្រង់ព្រះមេត្តាទទួលនូវគារវភក្តីភាពដ៏ខ្ពង់ខ្ពស់បំផុតពីទូលព្រះបង្គំយើងខ្ញុំ ។**

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

ឯក សំអុល